**តំបន់បាតសមុទ្រអន្តរជាតិ** (the Area)

**-តំបន់បាតសមុទ្រអន្តរជាតិ** (Area) គឺជាតំបន់បាតសមុទ្រដែលនៅហួសពីខ្ពង់រាបបាតសមុទ្ររបស់រដ្ឋ។ វាត្រូវបានចាត់ជាតំបន់ហួសយុត្តាធិការជាតិ។

-តំបន់នេះនិងធនធានធម្មជាតិនៅទីនោះ ត្រូវបានចាត់ទុកថាជាបេតិកភណ្ឌរួមរបស់មនុស្សជាតិ (common heritage of mankind) ហើយការប្រើប្រាស់តំបន់ និងធនធានធម្មជាតិ ត្រូវគោរពគោលការណ៍សន្តិភាព និងសន្តិសុខសកល។ ការរុករក និងការធ្វើអាជីវកម្មលើធនធាននៃបាតសមុទ្រអន្តរជាតិ ត្រូវធ្វើឡើងដោយមានការអនុញ្ញាត(អាជ្ញាបណ្ណ) ពី**អាជ្ញាធរបាតសមុទ្រអន្តរជាតិ** (International Seabed Authority) ដែលជាតំណាងនៃប្រជាជាតិទាំងអស់ ដើម្បីគ្រប់គ្រង ចាត់ចែងគម្រោងអាជីវកម្ម ស្នើដោយរដ្ឋ ឬស្ថាប័នឯកជន និងគ្រប់គ្រងភាគលាភ ដែលនឹងត្រូវបែងចែកជូនរដ្ឋទាំងអស់ (UNCLoS, មាត្រា១៣៦-១៣៧)។

-រដ្ឋទាំងអស់ទទួលបានផលពីតំបន់នេះ ចូលរួមការពារបរិស្ថានសមុទ្រនិងផ្ទេរបច្ចេកវិទ្យា។